# ប្រព័ន្ធអូស្ត្រាលីក្នុងការផ្តល់ព័ត៌មានអំពីគ្រោះអាសន្ន

MCCSA
Multicultural Communities Council of South Australia

សម្រាប់គ្រាអាសន្ននៅប្រទេសអូស្ត្រាលី យើងប្រើប្រព័ន្ធអូស្ត្រាលីក្នុងការផ្តល់ព័ត៌មានអំពីគ្រោះអាសន្នដែលមានបីថ្នាក់ ៖ មានការជូរពណ៌ស្របទៅតាមកម្រិតកើនឡើងនៃហានិភ័យចំពោះជីវិតមនុស្សនិងទ្រព្យសម្បត្តិ ហើយនិងសកម្មភាពដែលអ្នកត្រូវធ្វើដើម្បីរក្សាខ្លួនអ្នកនិងជនជាទីស្រឡាញ់របស់អ្នកឲ្យមានសុវត្ថិភាព។

**Advice (Yellow): ឱវាទ (ពណ៌លឿង)៖**
មានហេតុការណ៍មួយបានកើតឡើង។ ពុំមានគ្រោះថ្នាក់ដែលអាចកើតមានភ្លាមៗនោះទេ។ រក្សាការទទួលព័ត៌មានជាប់ជានិច្ចក្រែងស្ថានការណ៍មានការប្រែប្រួល។

**Watch and Act (Orange): តាមមើលនិងធ្វើសកម្មភាព (ពណ៌លឿងទុំ)៖**
ភាពគ្រោះថ្នាក់បានកើនឡើងខ្ពស់មួយកម្រិត។ ស្ថានភាពទាំងឡាយមានការប្រែប្រួល ហើយអ្នកត្រូវការចាប់ផ្តើមធ្វើសកម្មភាពភ្លាមដើម្បីការពារខ្លួនអ្នកនិងក្រុមគ្រួសារអ្នក។

**Emergency Warning (Red): ការផ្តល់ដំណឹងអំពីគ្រោះអាសន្ន (ពណ៌ក្រហម)៖**
ការផ្តល់ដំណឹងអាសន្នគឺជាការផ្តល់ដំណឹងកម្រិតខ្ពស់ជាងគេ។ អ្នកអាចស្ថិតក្នុងភាពគ្រោះថ្នាក់ ហើយត្រូវធ្វើសកម្មភាពភ្លាមតែម្តង។ ការពន្យាពេលណាមួយ ធ្វើឲ្យជីវិតរបស់អ្នកអាចមានគ្រោះថ្នាក់។
រូបសញ្ញាមួយចង្អោមសម្រាប់សំគាល់ភាពគ្រោះថ្នាក់ត្រូវបានបង្កើតឡើងសម្រាប់កម្រិតអាសន្ននិមួយៗ។
មានសញ្ញាសម្រាប់ព្យុះសៃក្លូន ភ្លើងឆេះព្រៃ ទឹកជំនន់ កំដៅខ្ពស់ខ្លាំង ខ្យល់ព្យុះ និងដទៃទៀត។
ដើម្បីមើលសញ្ញាទាំងនោះ សូមចូលទៅ www.australianwarningsystem.com.au
ក្នុងខណៈមានគ្រោះអាសន្ន ការផ្តល់ដំណឹងអំពីគ្រោះអាសន្នទាំងនេះនឹងមានធ្វើឲ្យមានបច្ចុប្បន្នភាពនៅក្នុងគេហទំព័រនៃ SES និង CFS ។
ចំពោះដំណឹងអាសន្នអំពីទឹកជំនន់ ខ្យល់ព្យុះ និង រលកកំដៅ សូមចូលទៅ www.ses.sa.gov.au/warnings
ចំពោះភ្លើងឆេះព្រៃ សូមចូលទៅ www.cfs.sa.gov.au/warnings

ការតាមដានស្ថានភាពហើយនិងការត្រៀមខ្លួនដើម្បីជំលៀសនៅពេលអាជ្ញាធរបញ្ជាឲ្យធ្វើ គឺជាការទទួលខុសត្រូវរបស់បុគ្គលគ្រប់រូប។

សារនេះផ្តល់ជូនលោកអ្នកដោយ Multicultural Communities Council of South Australia ជាផ្នែកមួយនៃគំរោងកាត់បន្ថយហានិភ័យពីគ្រោះមហន្តរាយ ឧបត្ថមថវិកាដោយរដ្ឋាភិបាលសហព័ន្ធអូស្ត្រាលី និងរដ្ឋាភិបាលនៃរដ្ឋអូស្ត្រាលីខាងត្បូង។